សួស្តី! នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការជិះរ៉ឺម៉កកង់បី បាទ អញ្ចឹងមធ្យោបាយធ្វើដំណើរ
គឺយើងមានច្រើនប្រភេទ មានដូចជាឡាន ម៉ូតូ កង់ រ៉ឺម៉ក និងរ៉ឺម៉កកង់បីជាដើម
អញ្ចឹងប្រសិនបើយើងអត់មានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន បានន័យថាយើងអត់មានម៉ូតូផ្ទាល់ខ្លួន
ឬក៏អត់មានឡានផ្ទាល់ខ្លួនទេ យើងអាចប្រើប្រាស់មធ្យោបាយសាធារណៈ
ដែលមានដូចជាឡានតាក់ស៊ី រ៉ឺម៉កកង់បី និងម៉ូតូឌុបជាដើម ជាក់ស្តែងនៅក្នុងរូបភាពមួយនេះ
គឺយើងនឹងនិយាយអំពីការជិះរ៉ឺម៉កកង់បី។

អញ្ចឹងយើងមកមើលរូបភាពទី ១ ទាំងអស់គ្នាតែម្តង នៅក្នុងរូបភាពទី ១
យើងឃើញមានមនុស្សប្រុសស្រីជាច្រើន អង្គុយនៅក្នុងកន្លែងមួយ អញ្ចឹងកន្លែងនោះ
មើលទៅដូចជាកន្លែងផឹកស៊ី ឬក៏កន្លែងក្លឹបរាត្រីជាដើម ដែលយើងឃើញថាមានមនុស្សជាច្រើន
កំពុងតែអង្គុយញ៉ាំស្រា និងអង្គុយស្តាប់ភ្លេង ដោយនៅទីនោះគឺមានភ្លេងកំដរ
អញ្ចឹងបានន័យថាពួកគេចេញមកក្រៅ ដើម្បីស្តាប់ភ្លេងកំដរនាថ្ងៃសម្រាក
ឬក៏បន្ទាប់ពីការបំពេញការងារនឿយហត់ អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ គឺមានតុចំនួនបី បាទ
ដែលមានមនុស្សជាច្រើននៅក្នុងតុនោះ ដែលយើងឃើញតុនៅកណ្តាល
គឺមានមនុស្សប្រុសស្រីចំនួនបីនាក់ អញ្ចឹងប្រុសស្រីចំនួនបីនាក់នោះគឺជាមិត្តភក្តិនឹងគ្នា
ដែលយើងឃើញបុរសទី ១ ដែលគាត់អង្គុយនៅខាងឆ្វេងដៃ បាទ គាត់អង្គុយនៅលើកៅអីមួយ
ដែលកៅអីនោះមានជើងកៅអីចំនួនបួន ហើយមានបង្អែកមួយផងដែរ
អញ្ចឹងគាត់អង្គុយលើកៅអីដោយដាក់ដៃនៅលើតុ ហើយគាត់ផ្អែកទៅលើបង្អែក
បុរសនោះពាក់អាវដៃខ្លីពណ៌បៃតង ហើយគាត់ស្លៀកខោជើងវែងពណ៌ស
ដែលគាត់ពាក់ស្បែកជើងប៉ាតា បុរសនោះមានអាយុប្រហែលជា ២០ ឆ្នាំ
ដែលគាត់មានសក់បះឡើងទៅលើ បាទ គាត់ធ្វើជាម៉ូត អញ្ចឹងម៉ូតសក់របស់គាត់គឺបះឡើងទៅលើ
គាត់អង្គុយជាមួយនឹងនារីម្នាក់ដែលអង្គុយនៅកណ្តាល នារីម្នាក់នោះ គឺគាត់ពាក់អាវរៀលកពណ៌ស
ដៃវែង ហើយគាត់ស្លៀកខោពណ៌ខ្មៅជើងវែង អញ្ចឹងនារីម្នាក់នោះ គាត់បានចងសក់បួងឡើងទៅលើ
អញ្ចឹងនៅពេលដែលយើងចងសក់បួងឡើងទៅលើ សម្រាប់នារី គេហៅថាបួង
នៅពេលដែលយើងចងសក់ឡើងទៅលើ គេហៅថាបួងសក់ អញ្ចឹងនារីម្នាក់នោះ គាត់ពាក់អាវដៃវែង
ហើយរៀលក ចំណែកបុរសម្នាក់ទៀតដែលជាមិត្តភក្តិរបស់គាត់ដែរនោះ គឺគាត់ពាក់អាវពណ៌ប្រផេះ
ដៃខ្លី ហើយស្លៀកខោជើងវែង អ្នកទាំងបីកំពុងតែអង្គុយទល់មុខគ្នា
ពួកគេកំពុងតែញ៉ាំស្រាបៀរម្នាក់មួយដបៗ ដើម្បីនិយាយគ្នាលេងអំពីការងារ ឬក៏អំពីការសិក្សា
បន្ទាប់ពីគេសម្រាក ឬក៏ចេញពីធ្វើការ បានន័យថាគេមកទីនេះ ដើម្បីស្តាប់ភ្លេងលំហែអារម្មណ៍
អញ្ចឹងគេមកដើម្បីស្តាប់ភ្លេងនិងលំហែអារម្មណ៍ ដោយការញ៉ាំ ជួបជុំគ្នាញ៉ាំអាហារជាមួយគ្នា
និងញ៉ាំស្រាបៀរបន្តិចបន្តួច ដែលយើងឃើញនៅលើតុរបស់ពួកគេ គឺមានដបស្រា ក៏ដូចជាកែវស្រា

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយនិងធុងដាក់ទឹកកកផងដែរ។ អញ្ចឹងទឹកកកគេដាក់នៅក្នុងធុងមួយ ទឹកកក យើងដាក់នៅក្នុង
យើងយកមកដាក់នៅក្នុងកែវ ហើយចាក់ស្រាចូលទៅក្នុងកែវ ដើម្បីឲ្យវាត្រជាក់
ដូច្នេះហើយទើបគេដាក់ទឹកកកនៅក្នុងធុងមួយ នៅពេលដែលយើងត្រូវការទឹកកក
យើងអាចយកទឹកកកនោះមកដាក់ក្នុងកែវស្រាយើងបាន។

ចូលមកដល់រូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថា នៅលើតុនេះ
នៅលើតុរបស់ពួកគេអម្បាញ់មិញ គឺមានស្រាចំនួនបីដប អញ្ចឹងពួកគេមកទីនេះ
គឺញ៉ាំភេសជ្ជៈគឺជាស្រា បាទ ដែលថាស្រាគឺមានច្រើនប្រភេទ មានដូចជាប៊ីយេរ មានដូចជាស្រាបៀរ
មានដូចជាស្រាក្រហម ឬក៏ស្រាវិស្គីជាដើម អញ្ចឹងស្រាគឺសុទ្ធតែមានជាតិអាល់កុលទាំងអស់
អញ្ចឹងវាអាចធ្វើឲ្យយើងស្រវឹងបាន អញ្ចឹងហើយនៅពេលដែលយើងស្រវឹង យើងមិនអាចបើកបរ
ឬក៏ធ្វើដំណើរបាននោះទេ ប្រសិនបើយើងស្រវឹង យើងមិនអាចបើកបរបាននោះទេ
ព្រោះវាខុសនឹងច្បាប់ ហើយបង្កឲ្យមានគ្រោះថ្នាក់ផងដែរ។ ម្យ៉ាងវិញទៀត ការញ៉ាំស្រា
គឺបណ្ដាលឲ្យប៉ះពាល់សុខភាព ដូច្នេះហើយយើងមិនត្រូវឲ្យញ៉ាំច្រើននោះទេ
អញ្ចឹងយើងញ៉ាំតែបន្តិចបន្តួចបានហើយ ព្រោះថានៅពេលដែលយើងញ៉ាំច្រើន
វាអាចប៉ះពាល់ដល់សុខភាពយើង វាអាចធ្វើឲ្យយើងឈឺ វាអាចធ្វើឲ្យយើងឈឺក្បាល
វាអាចធ្វើឲ្យយើងឈឺក្រពះជាដើម អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញថា
អ្នកទាំងបីកំពុងតែញ៉ាំស្រាម្នាក់មួយដប ហើយគេបានយកទឹកកកដែលនៅក្នុងធុង បាទ
មានធុងមួយដែលដាក់ទឹកកក គេយកទឹកកកដែលនៅក្នុងធុងនោះដាក់ចូលកែវរបស់គេ បាទ
អញ្ចឹងគេទាំងបីនាក់បានយកទឹកកកដាក់ចូលក្នុងកែវ
បន្ទាប់មកគេចាក់ស្រាចូលទៅក្នុងកែវរបស់គេដើម្បីញ៉ាំ អញ្ចឹងពួកគេញ៉ាំស្រាដើម្បីកំដរអារម្មណ៍
ហើយអង្គុយស្ដាប់ភ្លេងនៅក្នុងក្លឹប ដែលគេធ្វើបែបនេះ គឺបន្ទាប់ពីចេញពីធ្វើការ
ដើម្បីលំហែអារម្មណ៍។

ចូលមកដល់រូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា
ពួកគេទាំងបីនាក់បានហៅអ្នកបម្រើមក ដែលនៅក្នុងរូបភាពនេះយើងឃើញថា
ពួកគេទាំងបីនាក់ដដែលកំពុងតែអង្គុយនឹងតុ ហើយនៅលើតុរបស់ពួកគេ គឺមានស្រាចំនួនបីដប
ជាមួយនឹងកែវចំនួនបី ហើយនិងធុងទឹកកកចំនួនមួយ ដែលធុងទឹកកកនោះសម្រាប់ដាក់ទឹកកក
ហើយនារីម្នាក់ដែលអង្គុយកណ្ដាល គាត់បានលើកដៃមួយឡើងដើម្បីជាសញ្ញាហៅទៅដល់អ្នកបម្រើ
ឬក៏ម្ចាស់ហាង អញ្ចឹងគាត់លើកដៃជាសញ្ញាហៅអ្នកបម្រើឬក៏ម្ចាស់ហាងដើម្បីឲ្យមកគិតលុយ
ពេលនោះគាត់ក៏បានប្រាប់ទៅម្ចាស់ហាងថា គាត់ញ៉ាំស្រាចំនួនអស់បីដប
អញ្ចឹងបានន័យថាគាត់ញ៉ាំតែចំនួនបីដបតែប៉ុណ្ណោះ គឺបានន័យថាគាត់ញ៉ាំតែបន្តិចទេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ព្រោះប្រសិនបើញ៉ាំច្រើន អាចធ្វើឲ្យគាត់ស្រវឹងខ្លាំង ឬក៏បណ្ដាលឲ្យគាត់មានគ្រោះថ្នាក់
ឬក៏ប៉ះពាល់ដល់សុខភាពគាត់ជាដើម ដូច្នេះហើយគាត់ញ៉ាំស្រាតែចំនួនបីដប សម្រាប់គ្នាបីនាក់
បានន័យថាម្នាក់មួយដប អញ្ចឹងនៅពេលដែលគាត់ញ៉ាំរួចហើយ ភ្លេងក៏បញ្ចប់
បន្ទាប់មកគាត់ក៏ហៅអ្នកបម្រើ ដើម្បីឲ្យមកគិតលុយ ពេលនោះអ្នកបម្រើក៏មក
ដែលយើងឃើញអ្នកបម្រើគឺគាត់ពាក់អាវពណ៌ខៀវដៃខ្លី ហើយគាត់រាងចំណាស់បន្តិចមើលទៅ
ដោយក្នុងដៃរបស់គាត់គឺមានកាន់កូនសៀវភៅមួយនិងប៊ិចមួយដើម
ដើម្បីកត់ត្រានូវអ្វីដែលភ្ញៀវចង់បាន បានន័យថានៅពេលដែលគាត់កាន់បែបនេះ
នៅពេលដែលភ្ញៀវហៅគាត់ គាត់មក ហើយនៅពេលដែលភ្ញៀវកុម្ម៉ង់អ្វីផ្សេងញ៉ាំ
គាត់អាចកត់ត្រាចូលទៅក្នុងកូនសៀវភៅនោះបានដើម្បីកុំឲ្យភ្លេច។

ចូលមកដល់រូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា បន្ទាប់ពីពួកគេហៅអ្នកបម្រើ
ដើម្បីឲ្យមកគិតលុយហើយ ពួកគេក៏រង់ចាំមួយសន្ទុះ អញ្ចឹងបានន័យថា
នៅពេលដែលអ្នកបម្រើមកដល់ ឃើញនៅលើតុរបស់ពួកគេបានកុម្ម៉ង់អ្វីខ្លះហើយ
គេក៏កត់ត្រាដើម្បីយកទៅគិតលុយ អញ្ចឹងអំឡុងពេលដែលគេគិតលុយ អ្នកទាំងបីនោះ
ត្រូវរង់ចាំបន្តិច ដោយយើងឃើញនៅក្នុងរូបភាពនេះគឺហាងនោះគឺបានបិទភ្លេងទៅហើយ
អញ្ចឹងបានន័យថាភ្លេងបញ្ចប់ គេលែងចាក់ភ្លេងទៀតហើយ ហើយអ្នកដែលអង្គុយនៅតុក្បែរនោះ
គឺទៅផ្ទះវិញទាំងអស់គ្នា អញ្ចឹងបានន័យថាដល់ម៉ោងដែលគេត្រូវបិទហាងហើយ
ដូច្នេះអ្នកដែលជាភ្ញៀវទាំងអស់ត្រូវត្រលប់ទៅផ្ទះវិញដើម្បីសម្រាក ជាក់ស្ដែងនៅក្នុងរូបភាពនេះ
យើងឃើញថាតុដែលនៅក្បែរៗពួកគេ ភ្ញៀវដែលអង្គុយនៅតុក្បែរពួកគេ
គឺឡើងត្រលប់ទៅផ្ទះទាំងអស់គ្នា ចំណែកឯពួកគេគឺនៅអង្គុយរង់ចាំបន្តិច ដើម្បីឲ្យម្ចាស់ហាង
ឬក៏អ្នកបម្រើ គាត់មកគិតលុយ។

ចូលមកដល់រូបភាពទី ៤ រូបភាពទី ៥ នៅក្នុងរូបភាពទី ៥ បន្ទាប់ពីពួកគេរង់ចាំមួយសន្ទុះក្រោយមក
អ្នកបម្រើក៏បានត្រលប់មកវិញ អញ្ចឹងអ្នកបម្រើត្រលប់មកវិញ
នៅពេលនោះអ្នកបម្រើបានប្រាប់អំពីតម្លៃ ដែលពួកគេត្រូវបង់ទៅឲ្យហាង ដោយតម្លៃអំពីមុខម្ហូប
ជាមួយនឹងស្រាបៀរដែលគេកំពុងញ៉ាំ អញ្ចឹងអ្នកបម្រើបានប្រាប់អំពីតម្លៃទៅដល់អ្នកទាំងបីថា
អស់ចំនួនប៉ុន្មាន អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា ប្រហែលជាអស់ចំនួន ៣០ ដុល្លារ
ដែលនៅក្នុងនោះយើងឃើញ បន្ទាប់ពីអ្នកបម្រើប្រាប់ទៅដល់អ្នកទាំងបីថា អស់ចំនួន ៣០ ដុល្លារ
ហើយ នារីម្នាក់ដែលអង្គុយនៅកណ្ដាល ក៏បានយកលុយចំនួន ៣០ ដុល្លារ ហុចទៅឲ្យម្ចាស់ហាង
ឬក៏អ្នកបម្រើ ដើម្បីបង់ថ្លៃម្ហូបហើយនិងស្រាដែលពួកគេបានញ៉ាំ
អញ្ចឹងពួកគេទាំងបីនាក់ញ៉ាំស្រាម្នាក់មួយដបជាមួយនឹងម្ហូបផ្សេងទៀតដែលនៅលើតុ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះហើយទើបអស់តម្លៃ ៣០ ដុល្លារ បន្ទាប់មកពួកគេក៏បានចូលលុយគ្នា
បានន័យថាពួកគេចេញចំណែកម្នាក់ ១០ ដុល្លារៗ ដើម្បីឲ្យទៅថ្លៃម្ហូប[នោះ]គេនោះ
អញ្ចឹងបានន័យថា ពួកគេចេញស្មើៗគ្នា បានន័យថាម្នាក់ ១០ ដុល្លារ ម្នាក់ ១០ ដុល្លារ
ដែលសរុបទៅចំនួន ៣០ ដុល្លារ បន្ទាប់មកនារីម្នាក់នោះក៏យកលុយនោះឲ្យទៅអ្នកបម្រើ
ដើម្បីបង់ថ្លៃម្ហូបនិងស្រា បន្ទាប់មក ដើម្បីពួកគេត្រលប់ទៅផ្ទះវិញ។

បន្ទាប់មកទៀតនៅក្នុងរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា
បន្ទាប់ពីពួកគេបានបង់លុយថ្លៃស្រា ឬក៏ថ្លៃម្ហូបរួចរាល់ហើយ ពួកគេក៏បានដើរត្រលប់ទៅផ្ទះ
អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ គឺពួកគេរៀងស្រវឹងបន្តិច ដោយសារតែគេញ៉ាំស្រាម្នាក់មួយដប
អញ្ចឹងបានធ្វើឲ្យពួកគេរៀងស្រវឹង អញ្ចឹងអាការៈស្រវឹងគឺយើងមានអារម្មណ៍ថាវិលមុខ
ឬក៏ឈឺក្បាលបន្តិចបន្តួច ហើយពេលខ្លះប្រសិនបើយើងញ៉ាំស្រាបៀរច្រើន ឬក៏ញ៉ាំស្រាច្រើន
វាបណ្តាលឲ្យយើងក្អួតផងដែរ ព្រោះថានៅពេលដែលជាតិអាល់កុលនៅក្នុងខ្លួនយើងច្រើន
វានឹងបណ្តាលឲ្យយើងក្អួត ឬក៏ឲ្យយើងឈឺក្បាល ដូច្នេះហើយយើងមិនត្រូវញ៉ាំស្រាបៀរ
ឬក៏ស្រាច្រើននោះទេ ជាក់ស្តែងនៅក្នុងរូបភាពទី ៦ នេះ អ្នកទាំងបីគឺញ៉ាំស្រាតែម្នាក់មួយដបៗ
តែប៉ុណ្ណោះ ក៏ប៉ុន្តែវាបានធ្វើឲ្យគេស្រវឹងបន្តិច ដែលធ្វើឲ្យពួកគេពិបាកក្នុងការដើរ
ហើយពួកគេមានអាការៈវិលមុខនិងឈឺក្បាល យើងឃើញនៅក្នុងរូបភាពនេះ
គឺបុរសដែលពាក់អាវពណ៌បៃតងដៃខ្លី គាត់បានយកដៃម្ខាងរបស់គាត់ទៅច្រត់ក្បាល
បានន័យថាគាត់កំពុងតែវិលមុខ អញ្ចឹងគាត់មានអាការៈស្រវឹង ពិបាកដើរ ដោយគាត់វិលមុខ
ហើយនារីនិងបុរសម្នាក់ទៀត គាត់កំពុងតែដើរបណ្តើរ និយាយគ្នាបណ្តើរ ដោយគាត់និយាយគ្នាលេង
ឬក៏គាត់និយាយគ្នាអំពីការងារ ឬក៏ការសិក្សាផ្សេងៗ
អញ្ចឹងបានន័យថាពួកគេបានញ៉ាំស្រាម្នាក់មួយដបហើយ បន្ទាប់មកពួកគេត្រលប់ទៅផ្ទះ
ដោយមានអាការៈស្រវឹងបន្តិចបន្តួច ប៉ុន្តែពួកគេមិនស្រវឹងខ្លាំងនោះទេ
ដោយពួកគេអាចទប់ស្មារតីរបស់ពួកគេបាន។

ចូលមកដល់រូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា បន្តិចក្រោយមក
ពួកគេបានដើរមកដល់កន្លែងរ៉ឺម៉កមួយ ដែលជាទូទៅ ជនបរទេស គេហៅថាទុកទុក
ប៉ុន្តែក្នុងភាសាខ្មែរយើងហៅថារ៉ឺម៉ក អញ្ចឹងរ៉ឺម៉កគឺមានច្រើន មានរ៉ឺម៉កកង់បួន និងរ៉ឺម៉កកង់បីផងដែរ
ដូច្នេះនៅក្នុងរូបភាពនេះ យើងឃើញថា ពួកគេបានសម្លឹងទៅមើលរ៉ឺម៉កកង់បីចំនួនមួយ
ដែលរ៉ឺម៉កនោះគឺមានពណ៌ផ្កាឈូក បាទ រ៉ឺម៉កគឺមានពណ៌ផ្កាឈូក ហើយមានដំបូល
អញ្ចឹងរ៉ឺម៉កគឺមានដំបូលផងដែរ គឺស្រដៀងទៅនឹងឡាន ក៏ប៉ុន្តែវាអត់មានកញ្ចក់
និងអត់មានម៉ាស៊ីនត្រជាក់នោះទេ ប្រសិនបើឡាន ឬក៏តាក់ស៊ីគឺមានកញ្ចក់សម្រាប់បិទ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងមានម៉ាស៊ីនត្រជាក់ ប៉ុន្តែសម្រាប់រ៉ឺម៉កគឺអត់មានម៉ាស៊ីនត្រជាក់នោះទេ គឺវាគ្រាន់តែមានដំបូល ដើម្បីបាំងកុំឲ្យយើងក្ដៅនៅពេលដែលជិះហាលថ្ងៃតែប៉ុណ្ណោះ ប៉ុន្តែពេលនេះគឺជាពេលយប់ យើងឃើញថារាល់ក្លឹបរាត្រី ឬក៏ហាងស្រាបៀរជាច្រើន គឺគេតែងតែបើកនៅពេលយប់ អញ្ចឹងហើយបន្ទាប់ពីគាត់បញ្ចប់ការផឹកស៊ី បានន័យថាជាពេលយប់ អញ្ចឹងគាត់ដើរមកដល់ឃើញរ៉ឺម៉កមួយ គាត់ ពួកគាត់មានបំណងចង់ជិះរ៉ឺម៉កនោះទៅផ្ទះ ដោយយើងឃើញម្ចាស់រ៉ឺម៉កកំពុងតែអង្គុយជក់បារីនៅក្នុងរ៉ឺម៉ក អញ្ចឹងបានន័យថាម្ចាស់រ៉ឺម៉ក គាត់កំពុងតែអង្គុយនៅខាងក្រោយ ហើយគាត់អង្គុយដោយយកជើងមួយជាន់លើកង់ ជើងមួយទៀតសំយុងចុះក្រោម ដោយគាត់យកដៃទាំងពីរដាក់លើជង្គង់ ហើយអង្គុយជក់បារី ដែលយើងឃើញថាជក់បារី គឺបណ្ដាលឲ្យប៉ះពាល់ដល់សុខភាព និងមានក្លិនមិនល្អនោះទេ ព្រោះថាផ្សែងបារីគឺមានធុំក្លិនស្អុយ ដូច្នេះហើយវាមិនល្អនោះទេសម្រាប់ការជក់បារី ហើយនៅក្នុងរូបភាពទី ៦ នេះ ៧ នេះ គឺនៅខាងក្រោយរ៉ឺម៉កនោះ យើងឃើញមានកន្លែងលក់អាហារមួយកន្លែង ដូចជាមីឆា បានន័យថា ទោះបីជាពេលយប់ក៏ដោយ នៅពេលដែលយើងនៅតាមផ្លូវ គឺមានកន្លែងលក់មីឆាជាច្រើន នៅក្នុងប្រទេសកម្ពុជា ទោះបីជាយប់ ស្មើណាក៏ដោយ ទោះបីជាយប់ជ្រៅ ពាក់កណ្ដាលអធ្រាត្រ ក៏យើងអាចរកអាហារញ៉ាំបានដែរនៅតាមផ្លូវ ព្រោះថានៅប្រទេសកម្ពុជា អាហារនៅតាមផ្លូវ គឺគេលក់ ២៤ ម៉ោង បានន័យថាគេបើកជាប់ជានិច្ចរហូតតែម្ដង អញ្ចឹងជាក់ស្ដែងនៅក្នុងរូបភាពនេះ យើងឃើញថា ទោះបីជាពួកគេចេញពីក្លឹបនៅក្នុងពេលយប់ជ្រៅក៏ដោយ ក៏យើងឃើញថាមានរទេះអាហារ ឬក៏រទេះមីឆា ឬក៏រទេះបបរ កំពុងតែលក់នៅតាមផ្លូវផងដែរ ដោយគាត់មិនទាន់បិទតូបនោះទេ។

ចូលមកដល់រូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថាពួកគេទាំងបីនាក់ បានដើរមករករ៉ឺម៉កកង់បីនោះ ដោយពេលនោះ គេបានចូលទៅកៀកនៅនឹងរ៉ឺម៉កកង់បី ដោយយើងឃើញរ៉ឺម៉កកង់បីនោះ គឺមានពណ៌ផ្កាឈូក ហើយកង់រ៉ឺម៉កគឺមានពណ៌ខ្មៅ រ៉ឺម៉កនោះគឺមានកង់ចំនួនបី ដែលកង់នៅខាងក្រោយចំនួនពីរ ឯកង់នៅខាងមុខចំនួនមួយ ហើយកង់នៅខាងមុខ[គឺ]ជាចង្កូត អញ្ចឹងបានន័យថានៅពេលដែលត្រូវការបត់ គឺយើងកាច់ចង្កូត ដែលចង្កូតបញ្ជាកង់នៅខាងមុខចំនួនមួយនោះផងដែរ។ ដោយរ៉ឺម៉កនេះ គឺមានចង្កៀងចំនួនពីរ សម្រាប់បំភ្លឺផ្លូវ អញ្ចឹងបានន័យថាចង្កៀងរ៉ឺម៉កនេះ គឺមានចំនួនពីរ ដែល ចំនួនពីរ ហើយមានចង្កៀងបំភ្លឺផ្លូវចំនួនមួយ អញ្ចឹងបានន័យថាភ្លើងស៊ីញ៉ូ ឬក៏ចង្កៀងស៊ីញ៉ូចំនួនពីរ ភ្លើងបំភ្លឺផ្លូវចំនួនមួយ អញ្ចឹងនៅពេលដែលគាត់ត្រូវការបត់ឆ្វេងឬក៏បត់ស្ដាំ គាត់អាចប្រើប្រាស់ភ្លើងស៊ីញ៉ូដូចជាម៉ូតូ ដូចជាឡានដែរ អញ្ចឹងរ៉ឺម៉ករបស់គាត់ គឺមានខាងមុខ គឺមានចង្កៀងស៊ីញ៉ូចំនួនពីរ និងចង្កៀងបំភ្លឺផ្លូវចំនួនមួយ ចំណែកខាងក្រោយក៏មានអំពូល

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងមានចង្កៀងដូចគ្នា ពួកគេបានដើរមកដល់រ៉ឺម៉កនោះ ហើយក៏បាននិយាយទៅកាន់បុរស ដែលជាម្ចាស់រ៉ឺម៉ក ដែលកំពុងតែជក់បារី យើងឃើញនៅក្នុងរូបភាពនេះ ពួកគេមិនចូលទៅជិតម្ចាស់រ៉ឺម៉កនោះទេ ព្រោះម្ចាស់រ៉ឺម៉កគាត់ជក់បារី ដូច្នេះផ្សែងបារីគឺមានក្លិនមិនល្អ ហើយអ្នកជក់បារីតែងតែមានក្លិនមិនល្អដែរ បានន័យថាគាត់មានធុំក្លិនស្អុយមាត់ ឬក៏គាត់មានធុំក្លិនស្អុយផ្សែងបារី ហើយផ្សែងបារីធ្វើឲ្យយើងមានគ្រោះថ្នាក់ ព្រោះថានៅពេលដែលយើងជក់បារី ផ្សែងបារីធ្វើឲ្យខូចសួតរបស់យើង ឬក៏ឲ្យយើងមានបញ្ហាផ្លូវដង្ហើមជាដើម អញ្ចឹងហើយជាទូទៅប្រជាជន មនុស្ស ភាគច្រើនមិនចូលចិត្តអ្នកជក់បារីនោះទេ។

ចូលមកដល់រូបភាពទី ៩ នៅក្នុងរូបភាពទី ៩ បន្ទាប់ពីពួកគេចូលទៅកាន់រ៉ឺម៉កកង់បីហ្នឹងហើយ ពួកគេក៏បាននិយាយថ្លៃ តថ្លៃទៅដល់រ៉ឺម៉កកង់បី ថាពីកន្លែងក្លឹបនោះទៅផ្ទះរបស់គេយកចំនួនប៉ុន្មាន ពេលនោះម្ចាស់រ៉ឺម៉កកង់បីនោះក៏បានឆ្លើយថា ១០ ដុល្លារ អញ្ចឹងពួកគេក៏បានភ្ញាក់ផ្អើល ព្រោះថាតម្លៃនោះគឺថ្លៃខ្លាំងពេក ហើយយើងឃើញនៅក្នុងរូបភាពនេះ គឺអ្នកទាំងបីនោះ គាត់បានបញ្ចេញអាការៈភ្ញាក់ផ្អើល ដោយគាត់បានហាមាត់ធំៗ ហើយបើកភ្នែកធំៗ ដោយភ្ញាក់ផ្អើលថាហេតុអ្វីក៏ថ្លៃយ៉ាងនេះ ព្រោះផ្ទះរបស់គេនៅជិតនឹងកន្លែងដែលគេផឹកស៊ីនោះទេ ប៉ុន្តែរ៉ឺម៉កកង់បីនោះយកថ្លៃតម្លៃខ្លាំងណាស់ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងឃើញអ្នករត់រ៉ឺម៉កកង់បីនោះ គាត់ពុំបានចុះថ្លៃនោះទេ ដោយគាត់នៅតែអង្គុយនៅលើរ៉ឺម៉កកង់បី ហើយនិយាយទៅកាន់បុរសទាំងបីនាក់នោះ ការអង្គុយហើយនិយាយទៅកាន់អតិថិជនបែបនេះ គឺជាការមិនសមរម្យនោះទេ ព្រោះថានៅពេលដែលគេមកនិយាយជាមួយយើង ជាសុជីវធម៌ យើងត្រូវក្រោកឈរនិយាយទៅកាន់គេវិញ ព្រោះថាអ្នកដែលមកនិយាយជាមួយយើងគឺឈរ អញ្ចឹងយើងគួរតែឈរដើម្បីនិយាយជាមួយគេវិញ ដើម្បីជាការគួរសម និងរក្សាសុជីវធម៌ អញ្ចឹងជាទូទៅប្រសិនបើយើងកំពុងតែអង្គុយ ហើយមាននរណាម្នាក់ដើរមកសួរយើង យើងគួរតែងើបឈរ ដើម្បីនិយាយទៅកាន់គេវិញ ធ្វើបែបនេះ គឺគេហៅថាយើងមានសីលធម៌និងមានសុជីវធម៌ល្អជាមួយនឹងអ្នកដទៃ ប៉ុន្តែយើងឃើញនៅក្នុងរូបភាពទី ៩ នេះ បុរសដែលជាម្ចាស់រ៉ឺម៉កកង់បី គាត់ពុំបានក្រោកឈរនោះទេ ដោយគាត់នៅតែអង្គុយនៅលើរ៉ឺម៉ករបស់គាត់និយាយទៅកាន់អតិថិជនរបស់គាត់ ហើយគាត់បានយកតម្លៃខ្ពស់ខ្លាំងទៅកាន់អតិថិជនរបស់គាត់ ធ្វើឲ្យអតិថិជនរបស់គាត់ ដែលជាមិត្តភក្តិទាំងបីនាក់នោះ គឺមានការភ្ញាក់ផ្អើលនឹងតម្លៃនោះយ៉ាងខ្លាំង។

បន្ទាប់មកនៅក្នុងរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ បន្ទាប់ពីដឹងតម្លៃថាអ្នករត់រ៉ឺម៉កកង់បីនោះ គាត់យកតម្លៃ ១០ ដុល្លារ អ្នកទាំងបីក៏គិតថាតម្លៃនោះគឺថ្លៃខ្លាំងពេក

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះគាត់ពុំអាចទទួលយកបាននោះទេ អញ្ចឹងបានន័យថាផ្ទះរបស់គាត់នៅជិតកន្លែងផឹកស៊ី
ក៏ប៉ុន្តែម្ចាស់រ៉ឺម៉កកង់បី គាត់បានយកតម្លៃខ្ពស់ ឬក៏ថ្លៃខ្លាំងពេក
អញ្ចឹងហើយទើបអ្នកទាំងបីមិនអាចទទួលយកបាន
ដូច្នេះអ្នកទាំងបីក៏មិនសម្រេចចិត្តមិនជិះរ៉ឺម៉កកង់បីរបស់បុរសម្នាក់នោះទេ
អញ្ចឹងពួកគេក៏បានឆ្លើយទៅកាន់ម្ចាស់រ៉ឺម៉កកង់បីថា ពួកគេមិនជិះរ៉ឺម៉កកង់បីនោះទេ
ព្រោះតម្លៃនេះគឺថ្លៃខ្លាំងពេក ដូច្នេះហើយពួកគេនឹងរករ៉ឺម៉កកង់បីផ្សេងទៀត។

ចូលមកដល់រូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញថា
បន្ទាប់ពីពួកគេបដិសេធទៅលើរ៉ឺម៉កកង់បីនោះហើយ ពួកគេក៏បានបន្តដើរមកខាងមុខទៀត
អញ្ចឹងយើងឃើញថាអ្នកទាំងបីគាត់បានដើរ ដោយបុរសពាក់អាវប្រផេះដៃខ្លី
ស្លៀកខោសជើងវែងនោះ គាត់ដើរនៅខាងមុខ បន្ទាប់មកមាននារីដែលពាក់អាវដៃខ្លីរៀលក ខោខ្មៅ
គាត់ដើរនៅកណ្ដាល ហើយបុរសដែលពាក់អាវបៃតងដៃខ្លីហើយខោជើងវែងពណ៌សនោះ
គាត់ដើរនៅខាងក្រោយគេ ពួកគេទាំងបីនាក់ដើរនៅក្នុងអាការៈស្រវឹងបន្តិច
ដោយដើរទៅខាងមុខទៀត ព្រោះពួកគេមិនបានជិះរ៉ឺម៉កកង់បីនោះទេ ដោយសារតែម្ចាស់រ៉ឺម៉កកង់បី
គាត់ទារថ្លៃខ្លាំងពេក យើងឃើញនៅក្នុងរូបភាពនេះ បុរសដែលជាម្ចាស់រ៉ឺម៉កកង់បីនោះ
គាត់បានអង្គុយនៅលើកង់បីរបស់គាត់ ដោយបញ្ចេញទឹកមុខស្អុយ បានន័យថាយើងហៅថាមុខស្អុយ
ដែលទឹកមុខមិនសប្បាយចិត្ត អញ្ចឹងនៅពេលដែលយើងមិនសប្បាយចិត្ត
ឬក៏យើងធ្វើមុខមិនសប្បាយចិត្ត គេហៅថាមុខស្អុយ បានន័យថាយើងមិនសប្បាយចិត្តនោះទេ
ដោយបុរសម្នាក់នេះ គាត់កំពុងតែមិនសប្បាយចិត្ត ដោយសារអតិថិជនរបស់គាត់
មិនជិះរ៉ឺម៉កកង់បីរបស់គាត់ ព្រោះថាគាត់បានកាត់តម្លៃខ្លាំងពេក អញ្ចឹងអតិថិជនគាត់មិនជិះ
ហើយគាត់ដើរទៅមុខ ដែលធ្វើឲ្យគាត់ខកចិត្តនិងធ្វើមុខស្អុយ អង្គុយធ្វើមុខស្អុយ។

ចូលមកដល់រូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញថា
បន្ទាប់ពីពួកគេចេញពីរ៉ឺម៉កកង់បីទីមួយ បន្ទាប់មកពួកគេដើរបានបន្តិច
ក៏ជួបនឹងរ៉ឺម៉កកង់បីទីពីរមួយទៀត អញ្ចឹងយើងឃើញថា រ៉ឺម៉កកង់បីនោះ ម្ចាស់រ៉ឺម៉កកង់បី
គឺពុំបានជក់បារីនោះទេ ដោយម្ចាស់រ៉ឺម៉កកង់បី គឺគាត់ពាក់អាវដៃខ្លីពណ៌ស
ស្លៀកខោជើងវែងពណ៌ប្រផេះ អញ្ចឹងអ្នកទាំងបីបាននិយាយទៅកាន់រ៉ឺម៉កកង់បីនោះ
ដោយសួរតម្លៃពីកន្លែងដែលគាត់ផឹកស៊ី ឬក៏កន្លែងដែលគាត់កំពុងតែឈរ ទៅដល់ផ្ទះរបស់គាត់
តើគេយកចំនួនប៉ុន្មាន? បន្ទាប់មកម្ចាស់រ៉ឺម៉កកង់បី គាត់ក៏បានលូកដៃ
ឬក៏យកដៃមួយចំហៀងជ្រែងហោប៉ៅ ដោយការ គាត់យកដៃទៅលូកក្នុងហោប៉ៅ
ដោយកាយវិការបែបនេះ យើងហៅថាការជ្រែងហោប៉ៅ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយដៃម្ខាងទៀតរបស់គាត់លើកឡើងជាសញ្ញា ដើម្បីឲ្យអតិថិជនរបស់គាត់ចូលទៅក្នុងរ៉ឺម៉ក
ដោយគាត់ប្រាប់ថា ពីទីនេះទៅផ្ទះរបស់ពួកគាត់ គឺគាត់យកតម្លៃ ៥ ដុល្លារ
អញ្ចឹងអ្នកទាំងបីព្ញដូច្នេះហើយក៏សប្បាយចិត្ត ដូច្នេះពួកគេនិយាយថា
យល់ព្រមទៅជាមួយនឹងរ៉ឺម៉កកង់បីមួយនោះ។

ចូលមកដល់រូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា
បន្ទាប់ពីពួកគេតថ្លៃរ៉ឺម៉កកង់បីហើយ ពួកគេក៏បានយល់ព្រមជាមួយនឹងតម្លៃ ៥ ដុល្លារ
ដើម្បីជិះត្រលប់ទៅផ្ទះ យើងឃើញរ៉ឺម៉កកង់បីមួយនោះ គឺជារ៉ឺម៉កកង់បីដែលមានពណ៌ទឹកក្រូច
អញ្ចឹងស្រដៀងគ្នានឹងរ៉ឺម៉កកង់បីទីមួយដែរ ប៉ុន្តែរ៉ឺម៉កកង់បីទីមួយគឺមានពណ៌ផ្កាឈូក
ចំណែករ៉ឺម៉កកង់បីទីពីរគឺមានពណ៌ទឹកក្រូច ហើយម្ចាស់រ៉ឺម៉កកង់បីគឺជាមនុស្សមានសុជីវធម៌
ដោយគាត់បានក្រោកឈរនិយាយជាមួយអតិថិជន ហើយគាត់ពុំបានជក់បារីនោះទេ
ព្រោះថាគាត់ដឹងថាការជក់បារីធ្វើឲ្យខូចសុខភាព ហើយធ្វើឲ្យមានក្លិនមិនល្អ
ដែលបណ្ដាលឲ្យអតិថិជនរបស់គាត់មិនចូលចិត្ត ដូច្នេះគាត់មិនជក់បារីនោះទេ
អញ្ចឹងនៅក្នុងរូបភាពនេះគឺអ្នកទាំងបីក៏បានយល់ព្រមជិះរ៉ឺម៉កកង់បីរបស់បុរសម្នាក់នោះ ដោយនៅជិះ
យល់ព្រមជិះនៅក្នុងតម្លៃ ៥ ដុល្លារ ដើម្បីត្រលប់ទៅផ្ទះវិញ។

បន្ទាប់មកនៅក្នុងរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ បន្ទាប់ពីពួកគេយល់ព្រមនូវតម្លៃ ៥ ដុល្លារ
ដែលសម្រាប់ជិះរ៉ឺម៉កកង់បីនោះហើយ ម្ចាស់រ៉ឺម៉កកង់បីក៏បានចូលទៅក្នុងរ៉ឺម៉កដើម្បីបញ្ឆេះរ៉ឺម៉ក
ហើយបន្ទាប់មកពួកគេទាំងបីនាក់ក៏បានឡើងទៅលើរ៉ឺម៉ក អញ្ចឹងយើងឃើញថានៅក្នុងរូបភាពនេះ
បុរសដែលពាក់អាវពណ៌ប្រផេះជាមួយនឹងនារីដែលពាក់អាវរៀលកនេះ បានឡើងទៅមុន បាទ
ដោយបុរសពាក់អាវពណ៌ប្រផេះ គាត់បានជិះនូវចំហៀង ឬក៏ជិះនៅខាង ហើយនារីនោះ
គាត់ជិះនៅកណ្ដាល ហើយយើងឃើញនៅក្នុងរូបភាពនេះ បុរសដែលពាក់អាវស
គាត់បានយកដៃតោងបង្កាន់ដៃរ៉ឺម៉ក អញ្ចឹងបានន័យថាគាត់ជិះនៅខាង ដូច្នេះ
ដើម្បីកុំឲ្យមានគ្រោះថ្នាក់ គាត់ត្រូវតោងបង្កាន់ដៃរបស់រ៉ឺម៉ក ដែលនៅខាងលើ
ព្រោះថារ៉ឺម៉កកង់បីគឺអត់មានទ្វារនោះទេ អញ្ចឹងហើយប្រសិនបើយើងមិនតោងនោះទេ វាអាច
វាអាចនឹងធ្វើឲ្យយើងធ្លាក់បាន អញ្ចឹងដើម្បីសុវត្ថិភាពយើងត្រូវតែតោង ហើយនៅក្នុងរូបភាពនេះ
យើងឃើញថាបុរសពាក់អាវបៃតង បាទ គាត់ឡើងលើរ៉ឺម៉កក្រោយគេ បន្ទាប់ពីរ៉ឺម៉កឆេះហើយ
អញ្ចឹងបានន័យថាគាត់បញ្ឆេះម៉ាស៊ីន ម្ចាស់រ៉ឺម៉កគាត់បានបញ្ឆេះម៉ាស៊ីន
ដោយយើងឃើញនៅក្នុងរូបភាពនេះគឺរ៉ឺម៉កកំពុងតែ ម៉ាស៊ីនរ៉ឺម៉កកំពុងតែបញ្ឆេះ
ហើយរ៉ឺម៉កកំពុងតែរង្គើ បានន័យថានៅពេលដែលម៉ាស៊ីនបញ្ឆេះរួចរាល់ហើយ គឺរ៉ឺម៉ក ឬក៏ឡាន
ឬក៏ម៉ូតូ នឹងមានការរង្គើបន្តិច ព្រោះកម្លាំងម៉ាស៊ីនធ្វើឲ្យរ៉ឺម៉កនោះរង្គើ អញ្ចឹងបុរសដែលពាក់អាវបៃតង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់កំពុងតែយកជើងម្ខាងជាន់លើរ៉ឺម៉ក ជើងម្ខាងទៀតនៅលើដី
គាត់ធ្វើបែបនេះដើម្បីឡើងទៅលើរ៉ឺម៉ក ហើយដៃរបស់គាត់គឺតោងបង្កាន់ដៃរ៉ឺម៉កដែលនៅលើដំបូល
ដើម្បីកុំឲ្យធ្លាក់ អញ្ចឹងគាត់តោងដើម្បីឡើងលើរ៉ឺម៉ក ហើយអង្គុយ
ដើម្បីជិះត្រលប់ទៅផ្ទះរបស់គាត់វិញ។

បន្ទាប់មកទៀតរូបភាពចុងក្រោយគឺរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥
បន្ទាប់ពីគាត់បានឡើងលើរ៉ឺម៉កទាំងបីនាក់រួចរាល់ហើយ ម្ចាស់រ៉ឺម៉កក៏បានបញ្ជារ៉ឺម៉កឲ្យទៅមុខ
អញ្ចឹងម្ចាស់រ៉ឺម៉កគាត់ក៏បានមូលហ្គែរ ឬក៏គាត់មូលហ្គែរដើម្បីបញ្ជាឲ្យរ៉ឺម៉កគាត់ទៅមុខ
ដូច្នេះយើងឃើញនៅក្នុងរូបភាពនេះគឺម្ចាស់រ៉ឺម៉កគាត់ជិះលឿន បាទ អញ្ចឹងម្ចាស់រ៉ឺម៉កកង់បីនោះ
គាត់ជិះលឿន ដោយយើងឃើញរ៉ឺម៉ករបស់គាត់ហើបកង់មុខ បានន័យថាគាត់បង្ហោះកង់មុខ
បានន័យថាលឿន អញ្ចឹងគាត់ជិះលឿន ព្រោះថានៅពេលយប់គឺជាផ្លូវស្ងាត់
អញ្ចឹងពុំសូវមានមនុស្សធ្វើចរាចរណ៍នៅតាមផ្លូវនោះទេ ដូច្នេះហើយគាត់អាចជិះលឿនបាន
ក៏ប៉ុន្តែនៅពេលដែលយើងជិះម៉ូតូ ឬក៏ជិះឡាន ឬក៏ជិះរ៉ឺម៉ក យើងមិនត្រូវជិះលឿនពេកនោះទេ
ព្រោះវាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់បាន យើងហៅថាគ្រោះថ្នាក់ចរាចរណ៍
គឺប្រសិនបើមាននរណាម្នាក់រត់ឆ្លងកាត់ផ្លូវ ឬក៏មានឡានម៉ូតូផ្សេងទៀតដែលឆ្លងកាត់ផ្លូវ
វាអាចធ្វើឲ្យយើងប៉ះគ្នាឬក៏បុកគ្នា ដែលធ្វើឲ្យយើងមានគ្រោះថ្នាក់បាន អញ្ចឹង ទោះបីជាពេលយប់
ឬក៏ទោះបីជាផ្លូវស្ងាត់យ៉ាងណាក៏ដោយ យើងត្រូវបើកបរដោយគោរពច្បាប់ចរាចរណ៍
ដើម្បីរក្សាសុវត្ថិភាពរបស់យើង យើងមិនត្រូវជិះលឿនពេកនោះទេ ព្រោះវាធ្វើឲ្យយើងមានគ្រោះថ្នាក់
យើងឃើញថារ៉ឺម៉កកង់បីដែលមានបុរស[ទាំង] បុរសនិងមិត្តភក្តិរបស់គាត់ទាំងបីនាក់ជិះនោះ
បានបន្តដំណើរទៅខាងមុខ គឺសំដៅទៅផ្ទះរបស់ពួកគាត់ ដោយយើងឃើញមានរ៉ឺម៉កទីមួយ
ម្ចាស់រ៉ឺម៉កទីមួយ គាត់កំពុងតែអង្គុយជក់បារីនៅលើរ៉ឺម៉កគាត់ដដែល ក៏ប៉ុន្តែពួកគាត់ បុរសម្នាក់នោះ
គាត់ធ្វើមុខស្អុយ ដោយអតិថិជនរបស់គាត់មិនជិះរ៉ឺម៉ករបស់គាត់ ប៉ុន្តែបែរជាជិះរ៉ឺម៉ករបស់អ្នកដទៃ
ដោយសារតែគាត់យកតម្លៃថ្លៃពេក ហើយរ៉ឺម៉ករបស់អ្នកដទៃគឺយកតម្លៃថោក
ដូច្នេះអតិថិជនរបស់គាត់ក៏បានជិះទៅ ទៅ ទៅជិះរ៉ឺម៉កដែលមានតម្លៃថោកវិញ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.